ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
លេខ៖ បព ១៦០/២០២៦ កបទ.សអ

សេចក្តីប្រកាសព័ត៌មាន

លទ្ធផលនៃដំណើរទស្សនកិច្ចផ្លូវរដ្ឋរបស់ ឯកឧត្តម ផូល ខាហ្គាមេ
ប្រធានាធិបតី នៃសាធារណរដ្ឋរ៉ាន់ដា នៅព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី១២-១៤ ខែវិច្ឆិកា ឆ្នាំ២០២៦

តបតាមការអញ្ជើញរបស់**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា ឯកឧត្តម ផូល ខាហ្គាមេ (Paul KAGAME) ប្រធានាធិបតី នៃសាធារណរដ្ឋរ៉ាន់ដា និង**លោកជំទាវ ហ្សាណេត ខាហ្គាមេ** (Jeannette KAGAME) បានដឹកនាំគណៈប្រតិភូជាន់ខ្ពស់មកបំពេញទស្សនកិច្ចផ្លូវរដ្ឋ នៅព្រះរាជាណាចក្រកម្ពុជា ចាប់ពីថ្ងៃទី១២ ដល់ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ ២០២៦ ស្របពេលដែលឯកឧត្តមអញ្ជើញចូលរួមកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនីលើកទី២០ ដែលព្រះរាជាណាចក្រកម្ពុជា ធ្វើជាម្ចាស់ផ្ទះ ពីថ្ងៃទី១៥ ដល់ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ ២០២៦។

បន្ទាប់ពីពិធីស្វាគមន៍ជាផ្លូវការ ឯកឧត្តមប្រធានាធិបតី **ផូល ខាហ្គាមេ** និង**លោកជំទាវ** បានចូលបង្គំគាល់ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅព្រះបរមរាជវាំង។ បន្ទាប់មក **ឯកឧត្តមប្រធានាធិបតី** និង**លោកជំទាវ** បានអញ្ជើញដាក់កម្រងផ្កាគោរពព្រះវិញ្ញាណក្ខន្ធនៅវិមានឯករាជ្យ និងនៅមណ្ឌបព្រះបរមរូប **ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ "ព្រះបរមរតនកោដ្ឋ"** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់ជាទីបំផុត។

ឯកឧត្តមប្រធានាធិបតី បានជួបពិភាក្សាការងារប្រកបដោយផ្លែផ្កាជាមួយ**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភាកម្ពុជា ដើម្បីផ្លាស់ប្តូរទស្សនៈគ្នាលើការពង្រឹងទំនាក់ទំនងទ្វេភាគី និងការពង្រីកកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ។ ឯកឧត្តម ក៏បានជួបជាមួយ**សម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី** ប្រធានរដ្ឋសភា ដែលក្នុងឱកាសនោះ ភាគីទាំងពីរបានសង្កត់ធ្ងន់លើសារៈសំខាន់នៃការពង្រឹងទំនាក់ទំនងអន្តរសភា និងការជំរុញទំនាក់ទំនងរវាងប្រជាជននិងប្រជាជន ឱ្យកាន់តែជិតស្និទ្ធថែមទៀត។

ក្នុងជំនួបទ្វេភាគីរវាង **ឯកឧត្តម ផូល ខាហ្គាមេ** ប្រធានាធិបតី នៃសាធារណរដ្ឋរ៉ាន់ដា និង **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ភាគីទាំងពីរបានពិភាក្សាអំពីការពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការលើវិស័យសំខាន់ៗ រួមមាន សេដ្ឋកិច្ច ពាណិជ្ជកម្ម មេសុចរណ៍ ការបោសសម្អាតមីន និង បច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍។ ភាគីទាំងពីរក៏បានប្តេជ្ញារួមគ្នាក្នុងការប្រើប្រាស់សក្តានុពលសង្គម-សេដ្ឋកិច្ចរបស់ប្រទេសទាំងពីរឱ្យអស់លទ្ធភាព ដើម្បីជាផលប្រយោជន៍រួមសម្រាប់ប្រជាជននៃ

ប្រទេសទាំងពីរ ព្រមទាំងបន្តជំរុញកិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌពហុភាគី។ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសាធារណរដ្ឋវ៉ាន់ដា ដែលបានគាំទ្រកម្ពុជាក្នុងការធ្វើជាប្រធានដឹកនាំកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនីលើកទី២០ ឱ្យបានប្រកបដោយជោគជ័យ សំដៅលើកកម្ពស់សន្តិភាព ស្ថិរភាព សន្តិសុខ និងការអភិវឌ្ឍប្រកបដោយចីរភាពក្នុងសហគមន៍ហ្វ្រង់កូហ្វូនី។

បន្ទាប់ពីជំនួបពិភាក្សាទ្វេភាគីនេះ **សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី** និង**ឯកឧត្តមប្រធានាធិបតី** បានអញ្ជើញធ្វើជាសាក្សីក្នុងពិធីចុះហត្ថលេខាលើឯកសារទ្វេភាគីចំនួន៣ រួមមាន៖

១) កិច្ចព្រមព្រៀង ស្តីពីសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋវ៉ាន់ដា

២) អនុស្សរណៈនៃការយោគយល់គ្នា ស្តីពីកិច្ចសហប្រតិបត្តិការក្នុងវិស័យទេសចរណ៍ រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋវ៉ាន់ដា និង

៣) អនុស្សរណៈនៃការយោគយល់គ្នា រវាងក្រុមប្រឹក្សាអភិវឌ្ឍន៍វ៉ាន់ដា(RDB) និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC)។

ក្នុងឱកាសនោះផងដែរ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** បានប្រោសព្រះទាននូវព្រះរាជពិធីលៀងសាយភោជន៍ផ្លូវរដ្ឋ ជាកិត្តិយសជូន **ឯកឧត្តម ផូ ខាហ្គាម៉េ** ប្រធានាធិបតី នៃសាធារណរដ្ឋវ៉ាន់ដា និង**លោកជំទាវ ហ្សារណេត ខាហ្គាម៉េ**។

ដំណើរទស្សនកិច្ចផ្លូវរដ្ឋរបស់ **ឯកឧត្តម ផូលេ ខាហ្គាម៉េ** មកកាន់ព្រះរាជាណាចក្រកម្ពុជា ដែលជាដំណើរទស្សនកិច្ចលើកដំបូងរបស់ប្រមុខរដ្ឋ នៃសាធារណរដ្ឋវ៉ាន់ដា ចាប់តាំងពីប្រទេសទាំងពីរបានបង្កើតទំនាក់ទំនងការទូត គឺជាព្រឹត្តិការណ៍ដ៏មានសារៈសំខាន់ជាប្រវត្តិសាស្ត្រ និងបានបើកទំព័រថ្មីនៃទំនាក់ទំនងមិត្តភាពកាន់តែជិតស្និទ្ធ ព្រមទាំងកិច្ចសហប្រតិបត្តិការដ៏ល្អរវាងប្រទេសទាំងពីរ។

ថ្ងៃសៅរ៍ ៥រោច ខែកត្តិក ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២៦